APSARA AUTHORITY
រាជរដ្ឋាភិបាលនៃការិយាល័យ បុគ្គលិក និងសម្ភារៈ
លេខ: ០៣២ ៣៧
ថ្ងៃទី ... ម៉ោង ........

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
បញ្ជូនមកពី : ...
លេខចូល : ៥០១០៩
ថ្ងៃ 04 ខែ 02 ឆ្នាំ 14 ម៉ោង ...
បញ្ជូនទៅ : ... 05/02

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃអាជ្ញាធរ "អប្សរា"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែង តំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២/

ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពារតំបន់ និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"

- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរ "អប្សរា"
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

- ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃអាជ្ញាធរ "អប្សរា" ដូចខាងក្រោម ៖

១.ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២.ឯកឧត្តម **ឃឹម ប៊ុនសុង** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប អនុប្រធាន

៣.ឯកឧត្តម **ដុច តឿន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៤.ឯកឧត្តម **ម៉ែន សុផល** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៥.ឯកឧត្តម **ធិត ចន្ថា** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៦.ឯកឧត្តម **ឈន សុភាព** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៧.ឯកឧត្តម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរ "អប្សរា" សមាជិក

៨.ឯកឧត្តម**គីមរ៉ែត សំរេច**រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទីប្រឹក្សា

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប អគ្គនាយកអាជ្ញាធរ "អប្សរា" រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** 2/2

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ចម្លងជូន៖
- គ្រប់នាយកដ្ឋាន
"ដើម្បីជ្រាបជាពត៌មាន"
សៀមរាប ថ្ងៃទី 6 ខែ 2 ឆ្នាំ 2014
អគ្គនាយក